# សេចក្ដីជូនដំណឹងស្ដីពីការធ្វើបរិវសកម្ម
## “សញ្ញាបណ្ណសាជីវកម្មដំបូងបំផុតនៅកម្ពុជា លេខ១”
## របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីតធីត (ហត្ថាកសិករ)

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណៈជន មេត្តាជ្រាបថា ហត្ថាកសិករ បានទទួលការអនុញ្ញាត និងចុះបញ្ជីជាស្ថាពរ ពីគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.) លើទម្រង់ពាក្យស្នើសុំរួម និងឯកសារផ្ដល់ព័ត៌មាន សម្រាប់ការបោះផ្សាយលក់សញ្ញាបណ្ណសាជីវកម្មជាសាធារណៈ តាមរយៈសេចក្ដីសម្រេចលេខ ១៦៥ / ១៨ គ.ម.ក / ស.ស.រ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៨។ អាស្រ័យហេតុនេះ ហត្ថាកសិករ ដោយមានជំនួយពីក្រុមហ៊ុន អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យួរីធី ធ្វើជាក្រុមហ៊ុនធានាទិញមូលបត្រ សូមអញ្ជើញ វិនិយោគិនគុណវុឌ្ឍិ ដែលមានបំណងសុំធ្វើបរិវិសកម្ម អញ្ជើញដាក់ពាក្យស្នើសុំចូលរួមធ្វើបរិវិសកម្មនៃសំណើលក់សញ្ញាបណ្ណសាជីវកម្ម។

### ១. សង្ខេបអំពីសញ្ញាបណ្ណសាជីវកម្មដែលបោះផ្សាយលក់

- ថ្លៃលក់ក្នុងមួយឯកតាសញ្ញាបណ្ណសាជីវកម្ម÷ ១០០.០០០ រៀល (~២៥ ដុល្លារអាមេរិក)
- ប្រភេទសញ្ញាបណ្ណសាជីវកម្ម÷ សញ្ញាបណ្ណ បង្កើតអោយមានកាតព្វកិច្ចតាមរយៈការចុះបញ្ជីឈ្មោះ ហើយជាប្រភេទកាតព្វកិច្ចដែលគ្មានទ្រព្យធានា និងមិនមែនជាកាតព្វកិច្ចកម្រិតទាប (Unsubordinated)
- ចំនួនសញ្ញាបណ្ណសាជីវកម្មសរុបដែលបោះផ្សាយលក់÷ ១.២០០.០០០ សញ្ញាបណ្ណ
- ទំហំវិនិយោគអប្បបរមា÷ ២ ពាន់លានរៀល (~៥០ ម៉ឺនដុល្លារអាមេរិក)
- សម្រាប់តែវិនិយោគិន÷ បុគ្គលដែលមានគុណវុឌ្ឍិដែលរួមមាន “វិនិយោគិនស្ថាប័ន” និង “វិនិយោគិនធនវុឌ្ឍិ”

### ២. ការធ្វើបរិវសកម្ម

ក. ការបែងចែកសញ្ញាបណ្ណសាជីវកម្ម÷

| ល.រ | វិនិយោគិនគុណវុឌ្ឍិ | ទំហំបែងចែក | ភាគរយបែងចែក |
|---|---|---|---|
| ១ | វិនិយោគិនខឿនស្នូល (Cornerstone Investor) ÷<br>សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (International Finance Corporation) | ៨០ ពាន់លានរៀល<br>(~២០ លានដុល្លារអាមេរិក) | ៦៦,៦៧% |

| ល.រ | វិនិយោគិនគុណវុឌ្ឍិ | ទំហំបែងចែក | ភាគរយបែងចែក |
|---|---|---|---|
| ២ | វិនិយោគិនដែលធ្វើបរិវិសកម្ម | ៤០ ពាន់លានរៀល (~១០ លានដុល្លារអាមេរិក) | ៣៣,៣៣% |
| | សរុប | ១២០ ពាន់លានរៀល (~៣០លានដុល្លារអាមេរិក) | ១០០,០០% |

ខ. កាលបរិច្ឆេទធ្វើបរិវិសកម្ម÷ **ថ្ងៃទី ០៨ ខែ វិច្ឆិកា ដល់ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១៨** (ថ្ងៃធ្វើការ)

- ពេលព្រឹក÷ ចាប់ពីម៉ោង ០៨: ០០ ដល់ម៉ោង ១២: ០០
- ពេលថ្ងៃ÷ ចាប់ពីម៉ោង ១៣: ០០ ដល់ម៉ោង ១៧: ០០

គ. ទីកន្លែងធ្វើបរិវិសកម្ម (សម្រាប់ទទួលបាន ទម្រង់ពាក្យស្នើសុំរួម ឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្ម)÷

| ល.រ | ឈ្មោះក្រុមហ៊ុន | គេហទំព័រ | ទូរស័ព្ទលេខ |
|---|---|---|---|
| ១ | អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីយូរីធី | www.sbiroyal.com | (៨៥៥) ២៣ ៩៩៩ ៥៩៥ |

ឃ. នីតិវិធី÷

១) វិនិយោគិនត្រូវមានលេខអត្តសញ្ញាណវិនិយោគិនពី គ.ម.ក។

២) វិនិយោគិនត្រូវមានលេខគណនីជួញដូរមូលបត្រកម្មសិទ្ធិ (Securities Trading Account) នៅក្រុមហ៊ុនមូលបត្រណាមួយ ដែលបានទទួលអាជ្ញាប័ណ្ណពី គ.ម.ក។

៣) វិនិយោគិនត្រូវបំពេញពាក្យស្នើសុំចូលរួមធ្វើបរិវិសកម្ម (Subscription Form) នៅទីតាំងដូចបានបញ្ជាក់ខាងលើ។

៤) វិនិយោគិនត្រូវដាក់ពាក្យស្នើសុំចូលរួមធ្វើបរិវិសកម្មទៅកាន់ទីតាំងដូចបានបញ្ជាក់ខាងលើ និង**ដាក់ប្រាក់ចំនួន ១០០% នៃថ្លៃទិញសញ្ញាបណ្ណសាជីវកម្មសរុប។**

## ៣. ការប្រកាសអំពីលទ្ធផលនៃការធ្វើបរិវិសកម្ម

ហត្ថាកសិករ ជាមួយនឹងក្រុមហ៊ុន អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីយូរីធី នឹងប្រកាសលទ្ធផលនៃការធ្វើបរិវិសកម្ម ទៅកាន់វិនិយោគិន ក្រោយពីទទួលបានការអនុញ្ញាតពី គ.ម.ក។

**<u>សម្រាប់ព័ត៌មានបន្ថែមអំពីការធ្វើបរិវិសកម្ម សូមទំនាក់ទំនង</u>÷**

| ល.រ | ឈ្មោះក្រុមហ៊ុន | បុគ្គលសម្រាប់ទំនាក់ទំនង | អ៊ីម៉ែល | ទូរស័ព្ទលេខ |
|---|---|---|---|---|
| ១ | អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យូរីធី | លោកស្រី ឆាយ លីហួរ | lchhay@sbiroyal.com | (៨៥៥) ៧៧ ៣៣៣ ៦៣១ |
| | | កញ្ញា ប៉ាន់ រ័ត្នគន្ធា | rpann@sbiroyal.com | (៨៥៥) ៨៥ ២៧១ ៨១៩ |

